មជ្ឈមណ្ឌលឯកសារកម្ពុជា
DOCUMENTATION CENTER OF CAMBODIA

USAID
FROM THE AMERICAN PEOPLE

# សេចក្តីប្រកាសជ្រើសរើសអ្នកស្ម័គ្រចិត្តជំនាន់ទី៣

# គម្រោងស្តីពី ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើង នូវស្ថានភាពសុខភាព របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

(ការទទួលបានសេវាកម្មសុខភាព និងសេវាកម្មសង្គមសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម)

តួនាទី៖ អ្នកស្ម័គ្រចិត្តកម្ពុជា (CamboCorps)

គម្រោង៖ ការលើកកម្ពស់សិទ្ធិ និងធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

អង្គការ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

វិស័យ៖ សុខភាព និងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

បំណាត់ថ្នាក់បុគ្គលិក៖ អ្នកស្ម័គ្រចិត្ត

ប្រភេទបុគ្គលិក៖ ពេញម៉ោង និងក្រៅម៉ោង

ទីតាំង៖ ២៥ខេត្តក្រុង

ចាប់ផ្តើមការងារ៖ ថ្ងៃទី៧ ខែមករា ឆ្នាំ២០២២

## សេចក្តីសង្ខេប

គោលបំណងនៃគម្រោង **«ការលើកកម្ពស់សិទ្ធិ និងធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម»** គឺ (១) ធ្វើឲ្យប្រសើរឡើង នូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ទៅតាមគោលដៅដែលបានកំណត់ (២) លើកកម្ពស់ការយល់ដឹងអំពីសុខភាពសាធារណៈ និងការទទួលបានសេវាកម្មសុខភាពសម្រាប់អ្នករស់រានមាន ជីវិតពីរបបខ្មែរក្រហម និង (៣) ធ្វើការសិក្សាស្រាវជ្រាវអំពីស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ជាពិសេសនៅតាមសហគមន៍ដាច់ស្រយាលសម្រាប់ផ្តល់ជាព័ត៌មាន ក្នុងការរៀបចំជំនួយអភិវឌ្ឍន៍នាពេលអនាគតដល់ប្រជាជននិងសហគមន៍ទាំងនេះ។

**លក្ខខណ្ឌជ្រើសរើស៖**

១) ត្រូវតែជាសិស្សនិស្សិតកំពុងសិក្សាថ្នាក់វិទ្យាល័យ ឬមហាវិទ្យាល័យ ឬទើបតែបញ្ចប់ការសិក្សានៅថ្នាក់មហាវិទ្យាល័យ

២) មានអាយុចាប់ពី១៨ ដល់២៥ឆ្នាំ និងនៅលីវ

៣)	មានសមត្ថភាព និងភាពអំណត់ក្នុងការធ្វើការងារក្នុងភូមិដ្ឋានដែលខ្លួនរស់នៅ ឬភូមិក្បែរៗ

៤)	មានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេសបានបង្គួរ (ការនិយាយ)

៥)	ផ្តោតសំខាន់លើតម្រូវការ និងផ្តល់អទិភាពដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

៦)	ចូលចិត្តធ្វើការងារជាមួយមនុស្សចាស់ ឬជនពិការដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

៧)	ចេះប្រើប្រាស់កម្មវិធីកុំព្យូទ័រ និងទូរសព្ទស្មាតហ្វូនបានល្អ

៨)	មានការប្តេជ្ញាចិត្តក្នុងការធ្វើការងារយ៉ាងយោចណាស់ឲ្យបានរយៈពេល២ម៉ោងក្នុងមួយថ្ងៃ ឬ៨ម៉ោងក្នុងមួយសប្តាហ៍អំឡុងពេលចាប់ពី១ទៅ៣ខែ

៩)	ត្រូវមានអាកប្បកិរិយាថ្លៃថ្នូរ និងស្មោះត្រង់

១០)	ត្រូវមានគណនីធនាគារ (អេស៊ីលីដា)

**កម្រិតវប្បធម៌បន្ថែម (ប្រសិនបើមាន)៖**

១)	ធ្លាប់បានចូលរួមវគ្គសិក្សាខ្លី ឬមានបទពិសោធន៍ក្នុងវិស័យសុខភាពសាធារណៈវិទ្យាសាស្ត្រពេទ្យ សុខភាពផ្លូវចិត្ត ការថែទាំមនុស្សចាស់ និងជនពិការ ឬក្នុងវិស័យផ្សេងៗពាក់ព័ន្ធនឹងគម្រោងដូចជាសង្គមវិទ្យា អក្សរសាស្ត្រ ឬប្រវត្តិសាស្ត្រ

២)	មានចំណេះដឹងក្នុងការប្រើប្រាស់ពាក្យ ឬវាក្យសព្ទវេជ្ជសាស្ត្រ

៣)	មានបទពិសោធន៍ធ្វើការជាមួយមនុស្សចាស់ ឬជនពិការដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

៤)	ធ្លាប់បានចូលរួមវគ្គសិក្សាខ្លី ឬមានបទពិសោធន៍រៀនសូត្រ ឬធ្វើកិច្ចការស្រាវជ្រាវពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

**អត្ថប្រយោជន៍ទទួលបានពីការងារស្ម័គ្រចិត្ត៖**

- ប្រាក់ឧបត្ថម្ភ និងការចំណាយផ្សេងៗក្នុងសកម្មភាពការងារស្ម័គ្រចិត្ត
- ប្រាក់ឧបត្ថម្ភថ្លៃកាតទូរសព្ទ
- វិញ្ញាបនបត្របញ្ជាក់វគ្គសិក្សាខ្លីក្នុងមុខវិជ្ជាសុខភាពសាធារណៈ និងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

**សូមផ្ញើប្រវត្តិរូបសង្ខេប និងលិខិតចំណាប់អារម្មណ៍ទៅកាន់៖**

ផាត សិលា
ជំនួយការស្រាវជ្រាវ និងទំនាក់ទំនងសហគមន៍
អ៊ីមែល៖ truthsela.p@dccam.org
ទូរសព្ទ៖ ០១១ ៧៣៧ ០៤៧ ឬ ០១០ ៨៦៧ ០៣១

គីម សុវណ្ណដានី
អ្នកសម្របសម្រួលគម្រោង
អ៊ីមែល៖ truthdany.k@dccam.org
ទូរសព្ទ៖ ០១២ ៧១១ ១២៣